ជូនចំពោះអ្នកធ្វើការទាំងអស់គ្នា

クメール語

តើមានរឿងដែលពិបាកនៅកន្លែងធ្វើការដែរឬទេ?

ការប្រព្រឹត្តដែលបណ្តាលឲ្យខាតបង់ប្រយោជន៍ដូចជាការបញ្ឈប់កុងត្រាការងារ

ដោយសារមូលហេតុដូចជា ការមានផ្ទៃពោះ ការសម្រាលកូន និងការសុំច្បាប់ឈប់សម្រាកមើលថែកូនជាដើម

ជារឿងដែលច្បាប់បានហាមឃាត់

មិនថាកម្មករជនជាតិជប៉ុន រឺ កម្មករជនជាតិបរទេស(ប្រភេទវីសា)ក៏ដោយ

「ការបញ្ឈប់កុងត្រាការងារដោយសារការមានផ្ទៃពោះ」 ជារឿងដែលខុសច្បាប់

ត្រូវបានគេនិយាយថា
「មិនទទួលស្គាល់ការសុំច្បាប់ឈប់សម្រាកសម្រាលកូននិងមើលថែកូន」

ត្រូវបានគេនិយាយថា
「ប្រសិនបើធ្វើការបានតិចម៉ោង ត្រូវធ្វើជាបុគ្គលិកក្រៅម៉ោង」

ត្រូវបានគេទម្លាក់តំណែងនៅពេលសុំច្បាប់ឈប់សម្រាកមើលថែកូន

ត្រូវបានគេកាត់បន្ថយប្រាក់ខែ
នៅពេលសុំច្បាប់ឈប់សម្រាកមុននិងក្រោយពេលសម្រាលកូន

នៅពេលដែលប្រាប់ថាមានផ្ទៃពោះ
ត្រូវបានគេនិយាយថា
「មិនជួយបន្តវីសា」

ត្រូវបានគេបញ្ឈប់ការងារនៅពេលដែលសម្រាកការងារ
ដោយប្រើប្រាស់ 「វិធានការវ៉ែទាំសុខភាពមាតា」

ឧទាហរណ៍ • • •

ហេតុផលដូចខាងក្រោម
- មានផ្ទៃពោះ សម្រាលកូន
- សម្រាកការងារដោយសារចាញ់កូន
- សុំច្បាប់ឈប់សម្រាកមុន និងក្រោយសម្រាលកូន

បើទទួលបានការប្រព្រឹត្តបែបនេះជារឿងខុសច្បាប់!
- បញ្ឈប់កុងត្រាការងារ
- មិនត្រូវបន្តវីសាសម្រាប់ស្នាក់នៅ
- ត្រូវបានកាត់បន្ថយប្រាក់ខែ ជាដើម

សូមប្រាប់ពីឆន្ទៈទៅកាន់ក្រុមហ៊ុនឲ្យបានច្បាស់ថា 「ខ្ញុំចង់បន្តការងារក្រោយពេលសម្រាលកូនរួច (បន្ទាប់ពីសុំច្បាប់ឈប់សម្រាកមើលថែកូន)」

សូមមើលផ្នែកខាងក្រោយអំពីប្រព័ន្ធដែលអាចប្រើប្រាស់បានក្នុងអំឡុងពេលមានផ្ទៃពោះនិងពេលសម្រាលកូន

បន្ថែមពីលើនេះទៀត • • •

ប្រសិនបើអ្នកជួបនឹងការបៀតបៀននៅកន្លែងធ្វើការ
សូមពិនិត្យមើលខិត្តប័ណ្ណផ្សេងមួយទៀត

ひと、くらし、みらいのために
厚生労働省
Ministry of Health, Labour and Welfare
មន្ទីរការងារប្រចាំខេត្តក្រុង នាយកដ្ឋានគាំពារបរិស្ថាននិងសមភាពនៃការជួលបុគ្គលិក

ប្រព័ន្ធដែលអាចប្រើប្រាស់សម្រាប់ការមានផ្ទៃពោះ ការសម្រាលកូន និងការមើលថែកូន※

ប្រព័ន្ធនិងវិធានការដែល កម្មការិនីដែលមានផ្ទៃពោះ រឺ បានសម្រាលកូនអាចប្រើប្រាស់បាន	ប្រព័ន្ធនិងវិធានការ(មួយផ្នែក)ដែល កម្មករនិងកម្មការិនីអាចប្រើប្រាស់ប្រាស់បានក្នុងអំឡុងពេលមើលថែកូន
◆ **ការឈប់សម្រាកការងារមុន និង ក្រោយពេលសម្រាលកូន** អាចសម្រាកការងារពីរសប្តាហ៍មុនថ្ងៃសម្រាលរហូតដល់ចុងក្រោយ ជាទូទៅ ក្រោយសម្រាលកូនរយៈពេលប្រហែលប្រាំបីសប្តាហ៍ មិនអាចធ្វើការបានទេ ◆ **ការប្តូរទៅការងារដែលស្រាលៗងាយៗ** អំឡុងពេលមានផ្ទៃពោះ អាចទាមទារការប្តូរទៅធ្វើការងារស្រាលៗងាយៗ ◆ **វិធានការថែទាំសុខភាពមាតា** ប្រសិនបើមានការណែនាំពីគ្រូពេទ្យក្នុងពេលពិនិត្យផ្ទៃពោះជាដើម សូមជូនដំណឹងទៅក្រុមហ៊ុន ដើម្បីឲ្យចាត់វិធានការ ◆ **ការកំណត់ទៅលើការងារដែលមានគ្រោះថ្នាក់** ស្ត្រីមិនត្រូវធ្វើការងារដែលលើកទម្ងន់លើសកំណត់របស់ខ្លួនទេ រឺនៅកន្លែងដែលមានបញ្ហាញស្ទះនុលជាដើមនោះទេ ◆ **ពេលដដែលថែទាំកូន** ស្ត្រីដែលមានកូនអាយុតិចជាង១ឆ្នាំអាចធ្វើការស្នើសុំការសម្រាកដើម្បីថែទាំកូន ក្រៅពីម៉ោងសម្រាកទូទៅ ១ថ្ងៃ២ដង ក្នុង១ដង ៣០នាទី ◆ **ការកំណត់ទៅលើការធ្វើការថែមម៉ោង នៅថ្ងៃឈប់សម្រាក និងដល់យប់ជ្រៅ** ឃើងអាចធ្វើការស្នើឲ្យដកចេញនូវការធ្វើការថែមម៉ោង ធ្វើការថ្ងៃឈប់សម្រាក និងដល់យប់ជ្រៅបាន	◆ **ការឈប់សម្រាកមើលថែកូន** ជាទូទៅ អាចសម្រាកហូតដល់មួយថ្ងៃមុនកូនដល់ខួប១ឆ្នាំ។ ហើយក៏អាចធ្វើការបែងចែកការសម្រាកជាពីរផ្នែកផងដែរ ◆ **ការឈប់សម្រាកមើលថែកូនរបស់ឪពុកក្រោយពេលសម្រាលកូន (ការឈប់សម្រាកមើលថែកូននៅពេលកើត)** ក្នុងអំឡុង៨សប្តាហ៍ក្រោយពេលកូនកើត អាចធ្វើការសុំច្បាប់ឈប់សម្រាកមើលថែកូនរហូតដល់៤សប្តាហ៍ ដោយបែងចែកជា២ដង ក្រៅពីការឈប់សម្រាកមើលថែកូន ◆ **ការធ្វើការគិតម៉ោងសម្រាប់មើលថែកូន** សម្រាប់បុគ្គលិកដែលចិញ្ចឹមកូនអាយុតិចជាងពាក់ឆ្នាំ មានប្រព័ន្ធដែលធ្វើការគិតម៉ោងដែលអាចប្រើប្រាស់បានបើសិនជាចង់ ◆ **ការឈប់សម្រាកថែទាំកូន** បុគ្គលិកដែលចិញ្ចឹមកូនមិនទាន់ចូលសាលាបឋមសិក្សា អាចធ្វើការសុំច្បាប់ឈប់សម្រាករហូតដល់រយៈពេល៥ថ្ងៃក្នុង១ឆ្នាំ(ក្នុងករណីដែលមានកូនចាប់ពី២នាក់ម្តឯទៅ បានរហូតដល់១០ថ្ងៃ)ដើម្បីថែទាំកូនដែលមានជម្ងឺរីរាងកាយ ដោយអាចសម្រាកម្តងចាប់ពីរយៈពេល១ម៉ោង ◆ **ការកំណត់លើការងារថែមម៉ោង** ចំពោះបុគ្គលិកដែលចិញ្ចឹមកូនអាយុក្រោមពាក់ឆ្នាំ អាចធ្វើការស្នើសុំលុបបំបាត់ការថែមម៉ោងការងារបាន

※ការពន្យល់ពីប្រព័ន្ធនេះត្រូវបានសង្ខេប។ សម្រាប់លក្ខខណ្ឌលម្អិតសម្រាប់ស្នើសុំជាដើម សូមធ្វើការទំនាក់ទំនងទៅក្រុមហ៊ុនវិមន្ទីរការងារ

នៅពេលដែលចង់ដឹងលម្អិតពីប្រព័ន្ធ រឺ ក្នុងករណីមានបញ្ហាពាក់ព័ន្ធនឹងឈប់សម្រាកពេលមានផ្ទៃពោះ ពេលសម្រាលកូន និងពេលសម្រាកមើលថែកូនជាដើម សូមធ្វើការពិគ្រោះជាមួយមន្ទីរការងារប្រចាំខេត្តក្រុង នាយកដ្ឋានគាំពារបរិស្ថាននិងសមភាពនៃការជួលបុគ្គលិក។

ទោះបីជាមិនបញ្ចេញអត្តសញ្ញាណក៏ដោយ ទទួលការពិគ្រោះយោបល់ដែរ។ ភាពឯកជនរបស់អ្នកមកពិគ្រោះយោបល់ត្រូវបានរក្សាយ៉ាងតឹងរ៉ឹង។

ហើយប្រសិនបើមានការសំណូមពរ ក៏អាចធ្វើការពន្យល់អំពីច្បាប់និងប្រព័ន្ធទៅកាន់ក្រុមហ៊ុនបានផងដែរ។

បញ្ជីលេខទូរស័ព្ទរបស់មន្ទីរការងារប្រចាំខេត្តក្រុង នាយកដ្ឋានគាំពារបរិស្ថាននិងសមភាពនៃការជួលបុគ្គលិក

ខេត្តក្រុង	លេខទូរស័ព្ទ	ខេត្តក្រុង	លេខទូរស័ព្ទ	ខេត្តក្រុង	លេខទូរស័ព្ទ	ខេត្តក្រុង	លេខទូរស័ព្ទ
ហុកកៃដូ	011-709-2715	តូក្យូ	03-3512-1611	ស៊ីហ្គាក់	077-523-1190	ឌាហ្គាវ៉ា	087-811-8924
អាអូម៉ូរិ	017-734-4211	កាណាហ្គាវ៉ា	045-211-7380	ក្យូតូ	075-241-3212	អ៊ិហ៊ីមេ	089-935-5222
អ៊ីវ៉ាតិ	019-604-3010	នីហ្គាតា	025-288-3511	អូសាកា	06-6941-8940	ទ្ចយ	088-885-6041
មីយ៉ាហ្គី	022-299-8844	តុយ៉ាម៉ា	076-432-2740	ហ្យូហ្គូ	078-367-0820	ហ្ស៊ីអូកាក់	092-411-4894
អាគិតា	018-862-6684	អ៊ីសិហ្គាវ៉ា	076-265-4429	ណារ៉ា	0742-32-0210	សាហ្គាក់	0952-32-7218
យ៉ាម៉ាហ្គាតា	023-624-8228	ហ្វ៊ីគុយ	0776-22-3947	វ៉ាកាយ៉ាម៉ា	073-488-1170	ណាហ្គាសាគិ	095-801-0050
ហ្ស៊ីគីស៊ីម៉ា	024-536-4609	យ៉ាម៉ាណាស៊ិ	055-225-2851	តុតតូរ៉ি	0857-29-1709	ឃើម៉ាម៉ូតូ	096-352-3865
អ៊ីវ៉ាម៉ាគិ	029-277-8295	ណាហ្គាណូ	026-227-0125	ស៊ីម៉ាណរ៉ি	0852-31-1161	អយតាក់	097-532-4025
តិណូហ្គី	028-633-2795	ហ្គីហ្វ៊ូ	058-245-1550	អូកាយ៉ាម៉ា	086-225-2017	មីយ៉ាសាគិ	0985-38-8821
ហ្គ្លីម៉ា	027-896-4739	ស៊ីហ្ស៊ីអូកា	054-252-5310	ហ៊ីរ៉ូស៊ីម៉ា	082-221-9247	ឌាហ្គូស៊ីម៉ា	099-223-8239
សៃតាម៉ា	048-600-6210	ម៉ៃឈិ	052-857-0312	យ៉ាម៉ាហ្គីឈិ	083-995-0390	អូគិណាវ៉ា	098-868-4380
ឈិបាក់	043-221-2307	មីអ៊ិ	059-226-2318	តុគីស៊ីម៉ា	088-652-2718		

ម៉ោងធ្វើការ : ម៉ោង៨កន្លះព្រឹក～ម៉ោង៥:១៥នាទីល្ងាច (លើកលែងថ្ងៃសៅរ៍អាទិត្យ ថ្ងៃបុណ្យ ចុងឆ្នាំនិងដើមឆ្នាំ)

【ឯកសារយោង】 សេចក្តីសង្ខេបនៃច្បាប់ស្តីពីភាពស្មើគ្នានៃឱកាសការងាររបស់បុរសនិងស្ត្រី

ភាសាអង់គ្លេស ភាសាចិន ភាសាព័រទុយហ្គាល់ ភាសាម៉ៀតណាម ភាសាជប៉ុន

ជូនចំពោះអ្នកធ្វើការទាំងអស់គ្នា

クメール語

តើមានរឿងដែលពិបាកនៅកន្លែងធ្វើការដែរឬទេ ?

ការបៀតបៀននៅកន្លែងធ្វើការជាអំពើដែលមិនអាចលើកលែងឲ្យបាន។

សូមធ្វើការពិគ្រោះយោបល់ ប្រសិនបើអ្នកជួបនឹងបញ្ហាបែបនេះ។

មិនថាកម្មករជនជាតិជប៉ុន រឺ កម្មករជនជាតិបរទេស(ប្រភេទវីសា)ក៏ដោយ

ការបៀតបៀននៅកន្លែងធ្វើការ ※ ជាអំពើដែលមិនអាចលើកលែងឲ្យបាន។

※កន្លែងធ្វើការក៏រួមបញ្ចូលដូចជា កន្លែងចុះបេសកកម្មការងារ នៅក្នុងរថយន្តដែលប្រើសម្រាប់បំពេញការងារ និងកន្លែងជួបជាមួយអតិថិជនផងដែរ។

ឧទាហរណ៍ សកម្មភាពបែបនេះត្រូវបានចាត់ទុកជា

ការបៀតបៀន

ការបំពានទៅលើរាងកាយ

ត្រូវបានវាយដំ រឺ ទាត់ធាក់

ការបំពានទៅលើផ្លូវកាយ

បញ្ចេញកំហឹងនៅមុខបុគ្គលិកផ្សេងទៀតដោយនិយាយថា

「ភាសាជប៉ុនងាយៗមិនចេះដែរ !」

ការចាមចារហួសកំណត់

ការបង្ខំឲ្យធ្វើការងារដែលមិនមែនជាកាតព្វកិច្ច

ដូចជាបង្ខំឲ្យធ្វើការបកប្រែភាសាបរទេស

ការចាមចារដែលគិតជ្រុល

មិនមានផ្តល់ការងារអ្វីឲ្យធ្វើ

ការរំលោភបំពានលើបុគ្គល

ការរិះគន់ពីស្ថានភាពវប្បធម៌របស់ប្រទេសកំណើត

ការកាត់ផ្តាច់ទំនាក់ទំនង

ត្រូវបានមិត្តរួមការងារ រឺ ថ្នាក់លើបន្តមិនអើពើជាមួយ

ការបៀតបៀនផ្លូវភេទ

ត្រូវបានមេប៉ះចង្កេះរឺដើមទ្រូង

ហើយនៅពេលធ្វើការតវ៉ា ត្រូវបានផ្ទាស់ប្តូរទៅផ្នែកការងារធ្វើផ្សេងទៀតដែលទទួលគុណវិបត្តិ

ត្រូវបានមេបង្ខំឲ្យទៅញ៉ាំអាហារទីទៅដើរលេងជាមួយ

ហើយមានអារម្មណ៍ថាពិបាកទៅធ្វើការ

ការបៀតបៀនក្នុងការឈប់សម្រាកពេលមានផ្ទៃពោះ សម្រាលកូន និងមើលថែកូនជាដើម

ពេលពិភាក្សាពីការឈប់សម្រាកមុនពេលសម្រាលកូនជាមួយថ្នាក់លើ ត្រូវបានថ្នាក់លើនិយាយថា

「បើសិនជាសុំធ្វើឈប់ឈប់សម្រាក នឹងបញ្ឈប់ការងារ」

ពេលពិភាក្សាពីការស្នើសុំមិនធ្វើការមែមម៉ាង ត្រូវបានថ្នាក់លើនិយាយថា 「នឹងមិនធ្វើការ

តម្លើងឋានៈពេលធ្វើការវាយតម្លៃលើកក្រោយ」

របៀបដោះស្រាយនិងកន្លែងទទួលពិគ្រោះយោបល់នៅពេលទទួលការបៀតបៀន សូមមើលផ្នែកខាងក្រោយ

បន្ថែមពីលើនេះទៀត・・・

ប្រសិនបើអ្នកត្រូវបានទទួលគុណវិបត្តិដោយសារសុំធ្វើឈប់ឈប់សម្រាកពេលមានផ្ទៃពោះ សម្រាលកូន និងមើលថែកូនជាដើម

សូមពិនិត្យមើលខិត្តប័ណ្ណមួយផ្សេងទៀត

ひと、くらし、みらいのために
厚生労働省
Ministry of Health, Labour and Welfare
មន្ទីរការងារប្រចាំខេត្តក្រុង នាយកដ្ឋានគាំពារបរិស្ថាននិងសមភាពនៃការជួលបុគ្គលិក

ប្រសិនបើទទួលបានការបៀតបៀន

សូមប្រាប់ពីអារម្មណ៍របស់អ្នកឲ្យបានច្បាស់

ប្រសិនបើយើងនៅស្ងៀមមិននិយាយអ្វី

បញ្ហាអាចនឹងកាន់តែអាក្រក់ទៅៗ។

សូមនិយាយពីអារម្មណ៍ពិតរបស់អ្នកដូចជានិយាយថា

「សូមបញ្ឈប់」 「ខ្ញុំមិនចូលចិត្តទេ」

សូមធ្វើការពិភាក្សាជាមួយនឹងផ្នែកពិគ្រោះនៅក្នុងក្រុមហ៊ុន

ការបៀតបៀនមិនមែនជាបញ្ហាបុគ្គលនោះទេ តែវាជាបញ្ហារបស់ក្រុមហ៊ុន។ សូមធ្វើការពិគ្រោះយោបល់ជាមួយអ្នកទទួលបន្ទុកផ្នែកពិគ្រោះរបស់ក្រុមហ៊ុនដូចជាផ្នែកធនធានមនុស្សនិងការងារជាដើម រឺទៅកាន់ថ្នាក់លើដែលអាចទុកចិត្តបាន។

ប្រសិនបើពិបាកធ្វើការពិគ្រោះនៅក្នុងក្រុមហ៊ុន រឺ ទោះជាពិគ្រោះរួចហើយក៏មិនទទួលបានដំណោះស្រាយទេ សូមធ្វើការពិគ្រោះជាមួយទីភ្នាក់ងារខាងក្រៅដូចជាមន្ទីរការងារប្រចាំខេត្តក្រុង

※ការទទួលគុណវិបត្តិដោយសារតែធ្វើការពិគ្រោះយោបល់ជាដឿងដែលត្រូវបានហាមឃាត់

ក្រុមហ៊ុនទាំងអស់មានកាតព្វកិច្ចរៀបចំវិធានការដូចខាងក្រោមដើម្បីការពារមិនឲ្យមានការបៀតបៀន !

សម្រាប់ព័ត៌មានលម្អិត សូមមើលតាមលីងខាងក្រោម

1. ត្រូវបំភ្លឺពីគោលការណ៍របស់ម្ចាស់អាជីវកម្ម ឲ្យបានទូលំទូលាយ និង បង្រៀនឲ្យបានច្បាស់លាស់ទៅបុគ្គលិក
2. ត្រូវរៀបចំប្រព័ន្ធចាំបាច់ដើម្បីធ្លើយតបឲ្យបានត្រឹមត្រូវនៅពេលមានការពិគ្រោះ (ឬកម្មវិធីទាំងពាក្យបណ្តឹងផ្សេងៗ)
3. នៅពេលទទួលបានការពិគ្រោះយោបល់ ត្រូវធ្វើធ្លើយតបឲ្យបានលឿន និង សមស្រប
4. ត្រូវមានវិធានការដើម្បីលុបបំបាត់មូលហេតុដែលបង្ករឲ្យមានការបៀតបៀន
5. (ការការពារភាពឯកជន) វិធានការដែលត្រូវអនុវត្តរួមគ្នា

■ ខិត្តប័ណ្ណ (ភាសាជប៉ុន) ※ចាប់ពីទំព័រទី២០ :

https://www.mhlw.go.jp/content/11900000/001019259.pdf

■ សមាគមន៍គាំទ្រកន្លែងការងារដែលមានភាពរីករាយ

https://www.no-harassment.mhlw.go.jp/foreign_workers_jp

កន្លែងពិគ្រោះ (ឥតគិតថ្លៃ) : បញ្ជីលេខទូរស័ព្ទរបស់មន្ទីរការងារប្រចាំខេត្តក្រុង នាយកដ្ឋានគាំពារលក្ខខណ្ឌការងារ និងសមភាពនៃការជ្រើសរើសបុគ្គលិក

ខេត្តក្រុង	លេខទូរស័ព្ទ	ខេត្តក្រុង	លេខទូរស័ព្ទ	ខេត្តក្រុង	លេខទូរស័ព្ទ	ខេត្តក្រុង	លេខទូរស័ព្ទ
ហុកកៃដូ	011-709-2715	តូក្យូ	03-3512-1611	ស៊ីហ្គាក់	077-523-1190	ឌាហ្គាវ៉ា	087-811-8924
អាអូម៉ូរិ	017-734-4211	កាណាហ្គាវ៉ា	045-211-7380	ក្យូតូ	075-241-3212	អ៊ិហ៊ីមេ	089-935-5222
អ៊ីវ៉ាតិ	019-604-3010	ន៊ីហ្គាតា	025-288-3511	អូសាកា	06-6941-8940	ខូឈិ	088-885-6041
មីយ៉ាហ្គី	022-299-8844	តូយ៉ាម៉ា	076-432-2740	ហ្យូហ្គូ	078-367-0820	ហ្វូគីអូកាក់	092-411-4894
អាគិតា	018-862-6684	អ៊ីសិហ្គាវ៉ា	076-265-4429	ណារ៉ា	0742-32-0210	សាហ្គាក់	0952-32-7218
យ៉ាម៉ាហ្គាតា	023-624-8228	ហ្វូគុយ	0776-22-3947	វ៉ាកាយ៉ាម៉ា	073-488-1170	ណាហ្គាសាគិ	095-801-0050
ហ្វូគីស៊ីម៉ា	024-536-4609	យ៉ាម៉ាណាស៊ី	055-225-2851	តូតតូរ៉ី	0857-29-1709	ឃីម៉ាម៉ូតូ	096-352-3865
អ៊ីបារ៉ាគិ	029-277-8295	ណាហ្គាណូ	026-227-0125	ស៊ីម៉ាណ៊ី	0852-31-1161	អយតាក់	097-532-4025
តិឈិហ្គី	028-633-2795	ហ្គីហ្វូ	058-245-1550	អូកាយ៉ាម៉ា	086-225-2017	មីយ៉ាសាគិ	0985-38-8821
ហ្គីនម៉ា	027-896-4739	ស៊ីហ្ស៊ីអូកា	054-252-5310	ហ៊ីរ៉ូស៊ីម៉ា	082-221-9247	ឌាហ្គូស៊ីម៉ា	099-223-8239
សៃតាម៉ា	048-600-6210	ង៉ៃឈិ	052-857-0312	យ៉ាម៉ាហ្គីឈិ	083-995-0390	អូគិណាវ៉ា	098-868-4380
ឈិបាក់	043-221-2307	មីអ៊ី	059-226-2318	តូគីស៊ីម៉ា	088-652-2718		

ម៉ោងធ្វើការ : ម៉ោង៨កន្លះព្រឹក〜ម៉ោង៥:១៥នាទីល្ងាច (លើកលែងថ្ងៃសៅរ៍អាទិត្យ ថ្ងៃបុណ្យ ចុងឆ្នាំនិងដើមឆ្នាំ)

【ឯកសារយោង】 សេចក្តីសង្ខេបនៃច្បាប់ស្តីពីភាពស្មើគ្នានៃឱកាសការងាររបស់បុរសនិងស្ត្រី

ភាសាអង់គ្លេស | ភាសាចិន | ភាសាព័រទុយហ្គាល់ | ភាសាវៀតណាម | ភាសាជប៉ុន